ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# គោលការណ៍ណែនាំ
# អ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
## Guideline for Agriculture, Forestry and Fisheries Extension Specialist



រៀបចំដោយៈ
នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ឧបត្ថម្ភការបោះពុម្ព ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ឆ្នាំ២០២១

# អារម្ភកថា

ឯកសារស្តីពីគោលការណ៍ណែនាំអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រៀបចំឡើងដោយអនុលោមតាមគោលនយោបាយផ្សព្វផ្សាយកសិកម្ម នៅកម្ពុជា ដែលត្រូវបានអនុម័តដាក់ឱ្យប្រើប្រាស់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅឆ្នាំ២០១៥ ហើយស្របទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្ម ឆ្នាំ២០១៩-២០២៣ ដែលបានកំណត់ចក្ខុវិស័យដើម្បីប្រែក្លាយ"កសិកម្មកម្ពុជា ជាកសិកម្មទំនើបដែលមានលក្ខណៈប្រកួតប្រជែង បរិយាប័ន្ន ធន់នឹងការប្រែប្រួលអាកាសធាតុ និងនិរន្តរភាព ដែលនាំដល់ការកើនឡើងប្រាក់ចំណូលគ្រួសារកសិករ វិបុលភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជា" ព្រមទាំងបង្កើនប្រសិទ្ធភាពនៃការកាត់បន្ថយរហោស្ថានកម្ម ការគ្រប់គ្រងដី ធនធានព្រៃឈើ និងជលផលប្រកបដោយចីរភាព និងភាតរៈបរិស្ថាន រួមទាំងការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងស្ថាប័នសេវាគាំទ្រ និងអភិវឌ្ឍធនធានមនុស្សក្នុងវិស័យកសិកម្ម ឆ្លើយតបទៅនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលនីតិកាលទី៦នៃរដ្ឋសភា។

គោលការណ៍ណែនាំនេះ គឺជាមូលដ្ឋានគ្រឹះដែលពិពណ៌នាអំពីនីតិវិធីក្នុងការបង្កើតអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានដូចជា នីតិវិធីក្នុងការជ្រើសរើសសិក្ខាកាម ដំណើរការបណ្តុះបណ្តាល ការតាមដាន និងវាយតម្លៃ ការទទួលស្គាល់ជាផ្លូវការ និងតួនាទីភារកិច្ចរបស់អ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការផ្តល់សេវាផ្សព្វផ្សាយ និងប្រឹក្សាបច្ចេកទេសកសិកម្មទំនើប គុណភាពខ្ពស់ ដើម្បីធានាឱ្យកសិករ និងសហគមន៍កសិកម្មទទួលបានសេវាកម្មផ្សព្វផ្សាយកសិកម្ម និងព័ត៌មានបច្ចេកទេសកសិកម្មថ្មី សមស្រប ទាន់ពេលវេលា និងគ្រប់គ្រាន់តាមតម្រូវការចាំបាច់ប្រកបដោយភាពវៃឆ្លាត នវានុវត្តន៍ គុណភាព និងប្រសិទ្ធភាព ក្នុងបរិបទនៃបដិវត្តន៍ឧស្សាហកម្មទី៤ និងបច្ចេកវិទ្យាឌីជីថល។

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំ "គោលការណ៍ណែនាំអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ" ដោយបាន

រៀបចំជាសិក្ខាសាលាពិគ្រោះយោបល់ជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត គ្រឹះស្ថានអប់រំកសិកម្ម វិស័យឯកជន ដៃគូអភិវឌ្ឍន៍ ដែលអនុវត្តការងារពាក់ព័ន្ធនឹងវិស័យកសិកម្ម និងការងារផ្សព្វផ្សាយកសិកម្ម។ លើសពីនេះទៅទៀត ក្រុមការងារបច្ចេកទេសនៃនាយកដ្ឋានផ្សព្វផ្សាយកសិកម្មរុក្ខាប្រមាញ់និងនេសាទក៏បានស្រាវជ្រាវពីឯកសារគោលនយោបាយ និងយុទ្ធសាស្រ្តរបស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាគោលនយោបាយអភិវឌ្ឍន៍កសិកម្មឆ្នាំ២០២១-២០៣០ ដែលនឹងត្រូវដាក់ចេញដោយរាជរដ្ឋាភិបាលនាពេលខាងមុខនេះ និងឯកសារប្រទេសនានាដែលពាក់ព័ន្ធនឹងការងារផ្សព្វផ្សាយកសិកម្មផងដែរ ដើម្បីឆ្លើយតបទៅនឹងបរិបទដែលប្រទេសជាតិយើងកំពុងទទួលរងនូវផលប៉ះពាល់ពីវិបត្តិជាសាកលនៃការឆ្លងរាលដាលជំងឺកូវីដ-១៩នេះ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមថ្លែងអំណរគុណដល់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកពាក់ព័ន្ធទាំងអស់ ពិសេសក្រុមការងារបច្ចេកទេសនៃនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលបានចំណាយពេលវេលា និងចូលរួមផ្តល់ជាធាតុចូលក្នុងការរៀបចំគោលការណ៍ណែនាំអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្របទៅតាមបរិបទនៃការវិវត្តន៍វិស័យកសិកម្មនាពេលបច្ចុប្បន្ន និងដើម្បីឆ្លើយតបទៅនឹងគោលនយោបាយផ្សព្វផ្សាយកសិកម្មកម្ពុជា ក៏ដូចជាទស្សនៈរបស់ក្រសួងក្នុងការផ្តល់នូវការលើកទឹកចិត្តដល់អ្នកស្រាវជ្រាវកសិកម្ម ព្រមទាំងការសិក្សាអំពីលទ្ធភាពក្នុងការបង្កើត “បណ្ឌិតសភាវិទ្យាសាស្រ្តកសិកម្ម” នាពេលខាងមុខនេះផងដែរ។

ក្នុងនាមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខ្ញុំសូមថ្លែងអំណរគុណ និងសង្ឃឹមថា អង្គភាពជំនាញក្រោមឱវាទគ្រប់លំដាប់ថ្នាក់ត្រូវចូលរួមសហការអនុវត្តឱ្យបានសកម្មនូវគោលការណ៍ណែនាំតាមអភិក្រម “រដ្ឋ ឯកជន ដៃគូអភិវឌ្ឍន៍ និងសហគមន៍” ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ក្រោមការសម្របសម្រួលរបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ប្រាកដណាស់ថា គោលការណ៍នេះនឹងក្លាយជាឯកសារគោលដ៏សំខាន់ក្នុងការអភិវឌ្ឍអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និង

នេសាទ ដើម្បីបង្កើនសេវាផ្សព្វផ្សាយកសិកម្ម តាមតម្រូវការអ្នកប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់ និងសូមចូលរួមផ្ដល់នូវទស្សនៈស្ថាបនាបន្ថែមទៀតក្នុងន័យប្រែក្លាយគោលការណ៍ណែនាំនេះឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ។

ថ្ងៃ ខែ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

# មាតិកា

**អារម្ភកថា** **ទំព័រ**


**១. សេចក្តីផ្តើម....១**

**២. គោលបំណងនៃគោលការណ៍ណែនាំ....២**

**៣.លទ្ធផលរំពឹងទុក....២**

**៤. ជំហាននៃការអនុវត្ត....២**

**៥. ដំណើរការវគ្គបណ្តុះបណ្តាល....៤**

**៦. ការតាមដាន វាយតម្លៃ និងទទួលស្គាល់ជាអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ....៨**

**៧. តួនាទី និងភារកិច្ចរបស់អ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ....១០**

**៨.សន្និដ្ឋាន....១១**

ឧបសម្ព័ន្ធ....១២

ឧបសម្ព័ន្ធទី១: សេចក្តីជូនដំណឹងអំពីវគ្គបណ្តុះបណ្តាលអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ....១៣

ឧបសម្ព័ន្ធទី២: ពាក្យស្នើសុំចុះឈ្មោះចូលរៀន និងប្រវត្តិរូបសង្ខេប....១៥

ឧបសម្ព័ន្ធទី៣:លិខិតឧទ្ទេសនាមចូលរួមវគ្គបណ្តុះបណ្តាល....១៨

ឧបសម្ព័ន្ធទី៤: ប្រធានបទបណ្តុះបណ្តាល....១៩

ឧបសម្ព័ន្ធទី៥: ការវាយតម្លៃសមត្ថភាពអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ....២៤

ឧបសម្ព័ន្ធទី៦: តួនាទី និងភារកិច្ចអង្គភាពពាក់ព័ន្ធ....២៧

ឧបសម្ព័ន្ធទី៧: ប្រភេទលិខិតចាំបាច់សម្រាប់ដំណើរការបណ្តុះបណ្តាល....២៩

ឧបសម្ព័ន្ធទី៨: គំរូផែនការថវិកាសម្រាប់វគ្គបណ្តុះបណ្តាល....៣០

ឧបសម្ព័ន្ធទី៩: គំរូផែនការសកម្មភាព....៣១

**ឯកសារយោង....៣២**

## ១. សេចក្តីផ្តើម

ការផ្សព្វផ្សាយកសិកម្ម ដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍវិស័យកសិកម្ម។ សេវាផ្សព្វផ្សាយកសិកម្មបានចែករំលែកចំណេះដឹង បច្ចេកវិជ្ជា និងព័ត៌មានថ្មីជាមួយអ្នកប្រើប្រាស់ ជាពិសេសជួយតភ្ជាប់អ្នកផលិតទៅកាន់អ្នកពាក់ព័ន្ធផ្សេងទៀតនៅក្នុងអាជីវកម្មកសិកម្ម។ ការផ្សព្វផ្សាយកសិកម្ម គឺជាសេវាដ៏ចាំបាច់មួយសម្រាប់កែលម្អផលិតកម្មកសិកម្ម ដោយផ្លាស់ប្តូរការធ្វើកសិកម្មយថាផល ទៅជាការធ្វើកសិកម្មសម្រាប់ពាណិជ្ជកម្ម។

ការអភិវឌ្ឍធនធានមនុស្សលើការងារផ្សព្វផ្សាយកសិកម្មជាកម្លាំងចលករដែលមានសារៈសំខាន់ ដើម្បីផ្តល់សេវាផ្សព្វផ្សាយកសិកម្មឱ្យបានទូលំទូលាយដល់មូលដ្ឋាន និងដោះស្រាយបញ្ហាប្រឈមនានារបស់អ្នកប្រើប្រាស់សេវាដើម្បីទទួលបាន និងប្រើប្រាស់ចំណេះដឹង ព័ត៌មាន និងបច្ចេកទេសកសិកម្មបានតាមតម្រូវការ សំដៅលើកកម្ពស់ផលិតភាពកសិកម្ម ពិពិធភាវូបនីយកម្ម ពាណិជ្ជូបនីយកម្មកសិកម្ម និងបង្កើនការងារប្រាក់ចំណូល ដើម្បីលើកកម្ពស់សេដ្ឋកិច្ចគ្រួសារកសិករ។

គោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជាឆ្នាំ២០១៥ បានបញ្ជាក់ថា យ៉ាងហោចណាស់ត្រូវមានមន្ត្រីផ្សព្វផ្សាយកសិកម្មម្នាក់ (ជាអ្នកឯកទេស ឬទីប្រឹក្សាផ្សព្វផ្សាយកសិកម្ម) សម្រាប់បម្រើកសិករ ១០០០គ្រួសារ។ ដូចនេះទៅអនាគតចាំបាច់ត្រូវមានមន្ត្រី ២០០០នាក់ សម្រាប់បម្រើការផ្សព្វផ្សាយដល់គ្រួសារកសិករចំនួន ២លាន ហើយក្នុងផ្នែកសកម្មភាពការអភិវឌ្ឍធនធានមនុស្សបានចែងថាភ្នាក់ងារផ្តល់សេវាផ្សព្វផ្សាយកសិកម្មនៅកម្ពុជាយ៉ាងហោចណាស់ត្រូវមានបួនប្រភេទគឺៈ(១). អ្នកឯកទេសផ្សព្វផ្សាយកសិកម្ម (២).ទីប្រឹក្សាផ្សព្វផ្សាយកសិកម្ម (៣). ភ្នាក់ងារផ្សព្វផ្សាយឃុំ (៤). ភ្នាក់ងារផ្សព្វផ្សាយភូមិ។ ក្នុងចំណោមភ្នាក់ងារផ្សព្វផ្សាយទាំង៤ប្រភេទ អ្នកឯកទេសផ្សព្វផ្សាយកសិកម្ម គឺមានកម្រិតខ្ពស់ជាងគេ ហើយក៏ជាអ្នកផ្តល់ប្រឹក្សាបច្ចេកទេស បង្កើតផែនការកម្មវិធីផ្សព្វផ្សាយកសិកម្ម ផ្តល់វគ្គបណ្តុះបណ្តាល និងសម្របសម្រួលអនុវត្តការងារនៅក្នុងអង្គភាពរបស់ខ្លួន។ ដូច្នេះ ដើម្បីឱ្យអ្នកឯកទេសផ្សព្វផ្សាយកសិកម្មវុក្ខាប្រមាញ់ និងនេសាទ មានសមត្ថភាពអាចអនុវត្តការងារបានប្រកបដោយប្រសិទ្ធភាព

និងប្រសិទ្ធផល ទាមទារឱ្យមានគោលការណ៍ណែនាំស្តីពីអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលរៀបចំដោយ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមានការទទួលស្គាល់ជាផ្លូវការពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ២. គោលបំណងនៃគោលការណ៍ណែនាំ

១. ជាឯកសារគោលសម្រាប់ប្រើប្រាស់ក្នុងដំណើរការជ្រើសរើស និងផ្តល់វគ្គបណ្តុះបណ្តាលអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឱ្យមានគុណវុឌ្ឍិ។

២. ជំរុញការអភិវឌ្ឍ និងគ្រប់គ្រងធនធានមនុស្សសម្រាប់ការងារផ្សព្វផ្សាយកសិកម្ម។

៣. ដើម្បីលើកកម្ពស់សេវាផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្របតាមគោលនយោបាយផ្សព្វផ្សាយកសិកម្មកម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាព។

## ៣. លទ្ធផលរំពឹងទុក

១. គ្រឹះស្ថានអប់រំកសិកម្ម និងអង្គភាពផ្តល់សេវាផ្សព្វផ្សាយកសិកម្មនឹងមានឯកសារគោលដើម្បីអនុវត្តលើការផ្តល់វគ្គបណ្តុះបណ្តាលដល់អ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

២. បង្កើនធនធានមនុស្សលើការងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីលើកកម្ពស់សេវាផ្សព្វផ្សាយកសិកម្មឱ្យកាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផល។

## ៤. ជំហាននៃការអនុវត្ត

ដើម្បីសម្រេចបាននូវការអនុវត្តទៅលើគោលការណ៍ណែនាំ ស្តីពីអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គ្រឹះស្ថានអប់រំកសិកម្ម និងអង្គភាពផ្តល់សេវាផ្សព្វផ្សាយកសិកម្ម ត្រូវអនុវត្តទៅតាមជំហានដូចខាងក្រោម៖

១. ការជ្រើសរើសសិក្ខាកាម ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលឱ្យក្លាយជាអ្នកឯកទេស

ផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

២. ដំណើរការបណ្តុះបណ្តាលអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

៣. ការតាមដាន វាយតម្លៃ និងទទួលស្គាល់ជាផ្លូវការជាអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**<u>ដំណាក់កាលនៃការអនុវត្ត</u>**




## ៤.១ ការជ្រើសរើសសិក្ខាកាមចូលរួមវគ្គបណ្តុះបណ្តាល

យន្តការនេះអនុវត្តឡើងក្នុងគោលបំណងដើម្បីជ្រើសរើសសិក្ខាកាមដែលមានលក្ខណសម្បត្តិ និងសក្តានុពល ស្របតាមលក្ខណៈវិនិច្ឆ័យដែលបានចែងក្នុងគោលការណ៍ណែនាំ។ សិក្ខាកាមចូលរួមវគ្គបណ្តុះបណ្តាលឱ្យក្លាយជាអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវជ្រើសរើសចេញពីអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ វិស័យឯកជន ឬដៃគូអភិវឌ្ឍន៍។

### ៤.១.១ នីតិវិធីក្នុងការជ្រើសរើសសិក្ខាកាមចូលរួមវគ្គបណ្តុះបណ្តាល

ដំណើរការនៃការជ្រើសរើសសិក្ខាកាមដើម្បីចូលរួមវគ្គបណ្តុះបណ្តាលឱ្យក្លាយជាអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវអនុវត្តដូចតទៅ៖

ក. អង្គភាពរៀបចំវគ្គបណ្តុះបណ្តាលត្រូវបង្កើតក្រុមការងារជ្រើសរើសសិក្ខាកាម។

ខ. អង្គភាពរៀបចំវគ្គបណ្តុះបណ្តាលត្រូវផ្សព្វផ្សាយ និងជូនដំណឹងស្តីពីការជ្រើសរើសបេក្ខភាពយ៉ាងតិច ១៥ថ្ងៃ (គិតតែថ្ងៃបំពេញការងារ) (ឧបសម្ព័ន្ធទី១) ដើម្បីជ្រើសរើសសិក្ខាកាមដែលមានលក្ខណៈវិនិច្ឆ័យដូចតទៅ៖

- សញ្ជាតិខ្មែរ ទាំង ២ ភេទ មានអាយុចាប់ពី២២ឆ្នាំឡើងទៅ
- មានសញ្ញាបត្របរិញ្ញាបត្រផ្នែកកសិកម្ម ឬសញ្ញាបត្រដែលមានតម្លៃស្មើ

- មានបទពិសោធន៍លើការងារកសិកម្មយ៉ាងតិច២ឆ្នាំ
- ស្ម័គ្រចិត្តបម្រើការងារផ្សព្វផ្សាយកសិកម្មក្រោយទទួលបានវគ្គបណ្ដុះបណ្ដាលយ៉ាងតិច២ឆ្នាំ
- មានឆន្ទៈក្នុងការបំពេញការងារក្នុងមូលដ្ឋាន មានអាកប្បកិរិយាល្អ មានភាពស្មោះត្រង់ ព្យាយាម អត់ធ្មត់ មានការប្រាស្រ័យទាក់ទងល្អ ជាមួយអាជ្ញាធរ និងអ្នកពាក់ព័ន្ធ
- មានកាយសម្បទាមាំមួន
- ស្ត្រីត្រូវបានលើកទឹកចិត្ត។

គ. ផ្ញើពាក្យស្នើសុំចុះឈ្មោះចូលរៀនដោយមានភ្ជាប់នូវប្រវត្តិរូបសង្ខេបបេក្ខភាព (ឧបសម្ព័ន្ធទី២ និងទី៣) ជូនអង្គភាពរៀបចំវគ្គបណ្ដុះបណ្ដាលដើម្បីធ្វើការវាយតម្លៃ និងជ្រើសរើសបេក្ខភាពដែលមានសក្ដានុពល។

## ៥. ដំណើរការវគ្គបណ្ដុះបណ្ដាល

ដើម្បីឱ្យអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានលទ្ធភាព និងសមត្ថភាពបំពេញតួនាទីភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពខ្ពស់ សិក្ខាកាមជាអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវទទួលបានការបណ្ដុះបណ្ដាលស្ដីពី (១). ការផ្សព្វផ្សាយកសិកម្ម (៧០%) (២). បច្ចេកទេសកសិកម្មថ្មីៗ ដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (៣០%) (ឧបសម្ព័ន្ធទី៤)។ វគ្គបណ្ដុះបណ្ដាលត្រូវធ្វើឡើងចន្លោះពេលពី ៦ខែ ទៅ ៩ខែ ដែលត្រូវរៀបចំដោយអង្គភាពរៀបចំវគ្គបណ្ដុះបណ្ដាលក្រោមកិច្ចសហការជាមួយនាយកដ្ឋានផ្សព្វផ្សាយ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ប្រធានបទដែលត្រូវបណ្ដុះបណ្ដាលមានដូចខាងក្រោម៖

### ៥.១ ការផ្សព្វផ្សាយកសិកម្ម

❖ **ប្រព័ន្ធនៃការផ្សព្វផ្សាយកសិកម្ម**

- ទិដ្ឋភាពទូទៅ និងសារៈសំខាន់នៃការផ្សព្វផ្សាយកសិកម្ម និងសេវាកម្មប្រឹក្សាយោបល់

- ការផ្សព្វផ្សាយកសិកម្មក្នុងសតវត្សទី២១
- គោលនយោបាយផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅកម្ពុជា
- លំនាំដើម ដំណើរការ និងវិធីសាស្ត្រក្នុងការផ្សព្វផ្សាយកសិកម្ម
- គំរូផ្ទេរបច្ចេកវិទ្យា
- ការពង្រឹងប្រព័ន្ធផ្សព្វផ្សាយ និងប្រព័ន្ធប្រឹក្សាយោបល់
- ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងសកម្មភាពផ្សព្វផ្សាយកសិកម្ម
- ការធ្វើផែនការក្នុងការផ្សព្វផ្សាយ ការសរសេរគម្រោងស្នើសុំ ការតាមដាន និងវាយតម្លៃ
- ការគ្រប់គ្រងផ្អែកលើលទ្ធផល
- ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃប្រសិទ្ធភាពពីការទទួលយក និងការសាយភាយបច្ចេកទេសកសិកម្ម
- វិធីសាស្ត្រផ្សព្វផ្សាយចំនួន៥
    - កិច្ចសន្យាជួលអ្នកក្រៅ
    - ភាពជាដៃគូរវាងស្ថាប័នរដ្ឋ និងវិស័យឯកជន
    - គាំទ្រសហគមន៍កសិកម្ម/អង្គការកសិករ
    - ការរៀនសូត្រពីកសិករទៅកសិករ
    - សេវាផ្សព្វផ្សាយសាធារណៈដោយស្ថាប័នរដ្ឋ។

❖ **ការផ្សព្វផ្សាយកសិកម្មជនបទជាមួយកសិករខ្នាតតូច**

- និយមន័យ និងលក្ខណៈរបស់កសិករខ្នាតតូច និងកសិកម្មខ្នាតតូច
- ឧបសគ្គ និងភាពចាំបាច់ក្នុងការអភិវឌ្ឍកសិករខ្នាតតូច
- យុទ្ធសាស្ត្រ និងវិធីសាស្ត្រនៃការអភិវឌ្ឍកសិកម្មខ្នាតតូច
- ជោគជ័យ និងគំរូក្នុងការអភិវឌ្ឍកសិករខ្នាតតូច។

❖ **ការអភិវឌ្ឍន៍កសិកម្មប្រកបដោយនិរន្តភាព**

- សារៈសំខាន់ និងគោលគំនិតនៃកសិកម្មប្រកបដោយចីរភាព
- បច្ចេកទេស និងឥទ្ធិពលនៃការផ្តល់បច្ចេកវិទ្យាកសិកម្មប្រកបដោយចីរភាព

- ការគ្រប់គ្រងដីធ្លីប្រកបដោយនិរន្តរភាពក្នុងវិស័យកសិកម្ម
- កសិកម្មសរីរាង្គ
- ប្រព័ន្ធកសិកម្មចម្រុះតាមតំបន់ក្សេត្រ-បរិស្ថាន។

❖ **ការប្រាស្រ័យទាក់ទងក្នុងការងារកសិកម្ម**

- ការគ្រប់គ្រងចំណេះដឹងក្នុងការផ្សព្វផ្សាយកសិកម្ម រួមមាន ការជ្រើសរើសប្រព័ន្ធផ្សព្វផ្សាយការផលិតពហុព័ត៌មាន និងបណ្តាញព័ត៌មាន
- វិធីសាស្ត្រផ្សព្វផ្សាយដោយប្រើប្រព័ន្ធព័ត៌មានវិទ្យា (សេវាផ្តល់ព័ត៌មានបច្ចេកទេសកសិកម្មដល់កសិករ និងអតិថិជន កម្មវិធីទូរស័ព្ទដៃ គេហទំព័រ...)
- ហានិភ័យ និងវិបត្តិនៃទំនាក់ទំនងក្នុងវិស័យកសិកម្ម និងធនធានធម្មជាតិ។

❖ **ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងគម្រោង**

- ទ្រឹស្តីក្នុងភាពជាអ្នកដឹកនាំ និន្នាការ និងការអភិវឌ្ឍ
- វិធីសាស្ត្រក្នុងការដឹកនាំស្ថាប័នប្រកបដោយប្រសិទ្ធភាព
- សារៈសំខាន់ និងគោលការណ៍នៃការគ្រប់គ្រងគម្រោង
- ទស្សនទាន និងគំរូនានានៅក្នុងការធ្វើផែនការកម្មវិធី កិច្ចការរដ្ឋបាល ការគ្រប់គ្រង និងសម្របសម្រួល
- គំរូ និងវិធីសាស្ត្រតាមដាន និងវាយតម្លៃ
- ការវាយតម្លៃកម្មវិធីផ្សព្វផ្សាយកសិកម្ម និងសេវាប្រឹក្សាយោបល់។

❖ **ទីផ្សារកសិកម្ម និងការគ្រប់គ្រងអាជីវកម្ម**

- មូលដ្ឋានគ្រឹះ និងការអនុវត្តការគ្រប់គ្រងទីផ្សារកសិកម្ម និងការគ្រប់គ្រងធុរកិច្ចកសិកម្ម
- ភាពជាសហគ្រិនកសិកម្ម
- ការអភិវឌ្ឍសហគ្រាសខ្នាតតូច និងមធ្យម
- ការផ្សារភ្ជាប់ផលិតផលទៅកាន់ទីផ្សារ និងការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា

- វិធីសាស្ត្រផ្សព្វផ្សាយ និងគំរូ ដែលត្រូវបានអនុវត្តចំពោះការគ្រប់គ្រងទីផ្សារកសិកម្ម និងការគ្រប់គ្រងធុរកិច្ចកសិកម្ម
- ការចូលរួមចំណែកផ្នែកសេដ្ឋកិច្ច នៃការផ្សព្វផ្សាយកសិកម្ម ដល់ការអភិវឌ្ឍកសិកម្ម និងការអភិវឌ្ឍជនបទ។

❖ **តួនាទីយេនឌ័រ និងការបង្កើនសិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីក្នុងវិស័យកសិកម្ម**

- គោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម និងតួនាទីភារកិច្ចអ្នកពាក់ព័ន្ធ
- ការផ្តល់ ឬការបង្កើនសិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីក្នុងវិស័យកសិកម្ម។

## ៥.២ បច្ចេកទេសកសិកម្មថ្មីៗ ដែលឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

❖ **ការអនុវត្តកសិកម្មល្អ** Good Agricultural Practice ( CamGAP )៖

- និយមន័យនៃការអនុវត្តកសិកម្មល្អជាសកល Global Good Agricultural Practice ( GlobalGAP )
- និយមន័យនៃការអនុវត្តកសិកម្មល្អ
- ការអនុវត្តកសិកម្មល្អ ផ្នែកសុវត្ថិភាពចំណីអាហារ
- ការអនុវត្តកសិកម្មល្អ ដើម្បីគ្រប់គ្រងសុវត្ថិភាពចំណីអាហារ
- ប្រព័ន្ធផ្តល់វិញ្ញាបនបត្រសម្រាប់ការអនុវត្តកសិកម្មល្អ។

❖ **ការអនុវត្តការចិញ្ចឹមសត្វល្អ**

- និយមន័យនៃការអនុវត្តការចិញ្ចឹមសត្វល្អ
- ការអនុវត្តការចិញ្ចឹមសត្វល្អ ( កសិដ្ឋាន ចំណី ការគ្រប់គ្រងកសិដ្ឋាន ការគ្រប់គ្រងសុខភាពសត្វ ការដឹកជញ្ជូន ការរក្សាទុក និងការកត់ត្រា )
- ប្រព័ន្ធផ្តល់វិញ្ញាបនបត្រសម្រាប់ការអនុវត្តការចិញ្ចឹមសត្វល្អ។

❖ **វារីវប្បកម្ម**

- វារីវប្បកម្មដែលមានសក្តានុពល
- ការកែច្នៃផលិតផលជលផល។

❖ **ផលិតកម្មដំណាំកៅស៊ូដែលធន់នឹងការប្រែប្រួលអាកាសធាតុ**

- ផលិតកម្មដំណាំកៅស៊ូដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។

❖ **ព្រៃឈើ**

- ផលប្រយោជន៍នៃចម្ការឈើដាំសម្រាប់សេដ្ឋកិច្ច សង្គម និងគុណភាពដី
- ការប្រើប្រាស់ផល និងអនុផលព្រៃឈើប្រកបដោយនិរន្តរភាព
- ការគ្រប់គ្រងព្រៃឈើដោយមានការចូលរួម (សហគមន៍ និងវិស័យឯកជន)
- ការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព
- ការគ្រប់គ្រងបញ្ហាភ្លើងឆេះព្រៃ យន្តការបង្ការ និងទប់ស្កាត់។

❖ **ប្រព័ន្ធធានាដោយមានការចូលរួម**

- បរិបទក្នុងការធ្វើកសិកម្មរបស់កសិករខ្នាតតូច
- ជម្រើសអាទិភាពសម្រាប់កសិករខ្នាតតូច
- និយមន័យប្រព័ន្ធធានាដោយមានការចូលរួម
- អ្វីជាអត្ថប្រយោជន៍របស់ប្រព័ន្ធធានាដោយមានការចូលរួម
- គោលការណ៍គ្រឹះរបស់ប្រព័ន្ធធានាដោយមានការចូលរួម
- ជំរុញការអនុវត្តកសិកម្មសរីរាង្គ អនុលោមតាមប្រព័ន្ធធានាដោយមានការចូលរួម
- ដំណើរការរបស់ប្រព័ន្ធធានាដោយមានការចូលរួម និងការត្រួតពិនិត្យកសិដ្ឋានមុនពេលផ្តល់វិញ្ញាបនបត្របញ្ជាក់។

## ៥.៣. ទស្សនកិច្ចសិក្សា និងបទបង្ហាញ

- ការទស្សនកិច្ចសិក្សាទៅតាមកសិដ្ឋានរបស់កសិករគំរូដែលទទួលជោគជ័យក្នុងការងារកសិកម្ម
- ការធ្វើបទបង្ហាញពីចំណេះដឹង ជំនាញ និងបទពិសោធន៍ទាក់ទងនឹងការងារកសិកម្មរបស់សិក្ខាកាម។

# ៦. ការតាមដាន វាយតម្លៃ និងទទួលស្គាល់ជាអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ៦.១ ការតាមដាន និងវាយតម្លៃ

គោលបំណងក្នុងការតាមដាន និងវាយតម្លៃអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺដើម្បីកំណត់បាននូវប្រសិទ្ធភាព និងប្រសិទ្ធផលការងារបន្ទាប់ពីទទួលបានវគ្គបណ្តុះបណ្តាល និងអនុវត្តការងារជាក់ស្តែងនៅតាមអង្គភាពសាមី ដោយយោងទៅតាមតួនាទីភារកិច្ចរបស់ខ្លួន។ ម្យ៉ាងមួយវិញទៀត លទ្ធផលនៃការវាយតម្លៃក៏ជាព័ត៌មានសម្រាប់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គ្រឹះស្ថានអប់រំកសិកម្ម ឬអង្គភាពរៀបចំវគ្គបណ្តុះបណ្តាលក្នុងការកែលម្អកម្មវិធីសិក្សា និងវិធីសាស្ត្រសម្រាប់បណ្តុះបណ្តាលដល់អ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឱ្យកាន់តែល្អប្រសើរ។

### ៦.១.១ ដំណើរការនៃការតាមដាន និងវាយតម្លៃ

ការតាមដាន និងវាយតម្លៃ នឹងត្រូវដឹកនាំធ្វើឡើងដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយសហការជាមួយអង្គភាពដែលអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបំពេញការងារ។ ការតាមដាន និងវាយតម្លៃត្រូវធ្វើឡើងបន្ទាប់ពីអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបំពេញការងារបានយ៉ាងហោចណាស់មួយឆ្នាំ( ឧបសម្ព័ន្ធទី៥ )។

### ៦.១.២ សូចនាករនៃការតាមដាន និងវាយតម្លៃ

ការវាយតម្លៃអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវផ្អែកលើលក្ខខណ្ឌដូចខាងក្រោម៖

១. បានបំពេញការងារឆ្លើយតបទៅនឹងតួនាទី ភារកិច្ច និងការទទួលខុសត្រូវដែលបានចែងក្នុងគោលការណ៍ណែនាំ និង

២. ទទួលបានលទ្ធផលល្អក្នុងការតាមដាន និងវាយតម្លៃសមត្ថភាព ជាអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ៦.២ ការទទួលស្គាល់

ការទទួលស្គាល់អ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានគោលបំណងដើម្បីអាចឱ្យគាត់អាចបំពេញការងារផ្សព្វផ្សាយកសិកម្មបានពេញលេញ និងមានទំនុកចិត្តប្រកបដោយវិជ្ជាជីវៈក្រោយបានទទួលស្គាល់ជាផ្លូវការដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ជាងនេះទៅទៀត ងាយស្រួលដល់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្នុងការគ្រប់គ្រងទិន្នន័យនៃអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយធានាបាននូវប្រសិទ្ធភាពនៃការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ អ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងត្រូវទទួលការវាយតម្លៃពីសមត្ថភាពអនុវត្តការងាររបស់សាមីខ្លួន បន្ទាប់ពីបញ្ចប់វគ្គបណ្តុះបណ្តាល និងយកចំណេះដឹងទៅបម្រើអង្គភាពរបស់ខ្លួនបានរយៈពេល ១ឆ្នាំ បន្ទាប់ពីបញ្ចប់វគ្គបណ្តុះបណ្តាល។ ពិន្ទុនៃការវាយតម្លៃត្រូវទទួលបានយ៉ាងតិចចាប់ពី១៦ពិន្ទុឡើងទៅនៃពិន្ទុសរុបក្នុងការវាយតម្លៃដើម្បីទទួលបានការទទួលស្គាល់ជាផ្លូវការតាមរយៈសេចក្តីសម្រេចដែលចេញដោយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ៧. តួនាទី និងភារកិច្ចរបស់អ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

អ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានតួនាទី និងភារកិច្ចចម្បងដូចជា៖

- ជួយអង្គភាពក្នុងការរៀបចំកសាងផែនការអភិវឌ្ឍការផ្សព្វផ្សាយកសិកម្ម
- រៀបចំផែនការ ពង្រឹងសមត្ថភាពដល់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម
- រៀបចំផែនការសកម្មភាពផ្នែកផ្សព្វផ្សាយកសិកម្មជូនអង្គភាព ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន
- ជាអ្នកផ្តល់ការប្រឹក្សាលើការងារផ្សព្វផ្សាយកសិកម្មដល់អ្នកពាក់ព័ន្ធផ្សេងៗ ដែលផ្តល់សេវាផ្សព្វផ្សាយកសិកម្ម

- ទំនាក់ទំនង និងសហការ ការផ្តល់សេវាផ្សព្វផ្សាយជាមួយអង្គភាពជំនាញដៃគូអភិវឌ្ឍន៍ វិស័យឯកជន សហគមន៍កសិកម្ម និងក្រុមកសិករ
- វាយតម្លៃតម្រូវការវគ្គបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្ម
- រៀបចំ និងសម្របសម្រួលវគ្គបណ្តុះបណ្តាលជំនាញកសិកម្ម
- ផ្តល់ការបណ្តុះបណ្តាលជំនាញផ្សព្វផ្សាយកសិកម្មដល់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម
- ប្រមូល ស្រាវជ្រាវ ចងក្រងឯកសារមេរៀនថ្មីៗ និងវិភាគទិន្នន័យដែលពាក់ព័ន្ធនឹងការងារផ្សព្វផ្សាយកសិកម្ម
- រៀបចំ និងចងក្រងរបាយការណ៍ និងទិន្នន័យនៃការងារផ្សព្វផ្សាយកសិកម្ម និងធនធានមនុស្សផ្នែកផ្សព្វផ្សាយកសិកម្ម។

**សម្គាល់៖** សម្រាប់តួនាទី និងភារកិច្ចរបស់អង្គភាពពាក់ព័ន្ធមាននៅក្នុងឧបសម្ព័ន្ធទី៦។

## ៨.សន្និដ្ឋាន

នៅពេលដែលគោលការណ៍ណែនាំសម្រាប់អ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ គោលការណ៍នេះនឹងក្លាយជាមូលដ្ឋានគ្រឹះដ៏សំខាន់បំផុតក្នុងការអនុវត្តនូវនីតិវិធីក្នុងការជ្រើសរើស បណ្តុះបណ្តាល និងវាយតម្លៃទទួលស្គាល់អ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដើម្បីបង្កើតធនធានមនុស្សលើផ្នែកផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្នុងគោលបំណងឆ្លើយតបទៅនឹងតម្រូវការសេវាផ្សព្វផ្សាយកសិកម្ម។ គោលការណ៍ណែនាំអាចដំណើរការបានជោគជ័យ អាស្រ័យទៅលើការគាំទ្រ និងមានការចូលរួមពីវិស័យសាធារណៈ វិស័យឯកជន ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធទាំងអស់យ៉ាងសកម្មផងដែរ ហើយតម្រូវឱ្យមានការធ្វើបច្ចុប្បន្នភាពសមស្របទៅតាមតម្រូវការជាក់ស្តែង។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១: សេចក្តីជូនដំណឹងអំពីវគ្គបណ្តុះបណ្តាលអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**ក្បាលទំព័រលិខិត ( Letter head ) របស់អង្គភាពរៀបចំវគ្គបណ្តុះបណ្តាល**
**សេចក្តីជូនដំណឹង**
**ស្តីពីការជ្រើសរើសអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**យោង៖** - សៀវភៅគោលការណ៍ណែនាំសម្រាប់អ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។
- យោងតាមការចាំបាច់ក្នុងការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅតាមមូលដ្ឋាន

**ឈ្មោះអង្គភាពរៀបចំវគ្គបណ្តុះបណ្តាល**...................................
**សូមជូនដំណឹង**

ដល់មន្ត្រី បុគ្គលិក និងសាធារណៈជនមេត្តាជ្រាបថា អង្គភាព.............ត្រូវការជ្រើសរើសបេក្ខភាពចំនួន........នាក់ ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលស្តីពីអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដែលនឹងប្រព្រឹត្តទៅពីថ្ងៃ........ខែ.........ឆ្នាំ........ដល់ថ្ងៃ........ខែ.........ឆ្នាំ........ដែលបេក្ខភាពត្រូវមានលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

- សញ្ជាតិខ្មែរទាំង២ ភេទ មានអាយុចាប់ពី២២ឆ្នាំឡើងទៅ
- មានសញ្ញាបត្របរិញ្ញាបត្រផ្នែកកសិកម្ម ឬសញ្ញាបត្រដែលមានតម្លៃស្មើ
- មានបទពិសោធន៍លើការងារកសិកម្មយ៉ាងតិច២ឆ្នាំ
- ស្ម័គ្រចិត្តបម្រើការងារផ្សព្វផ្សាយកសិកម្មក្រោយទទួលបានវគ្គបណ្តុះបណ្តាលយ៉ាងតិច២ឆ្នាំ
- មានឆន្ទៈក្នុងការបំពេញការងារក្នុងមូលដ្ឋាន មានអាកប្បកិរិយាល្អ មានភាពស្មោះត្រង់ព្យាយាមអត់ធ្មត់ មានការប្រាស្រ័យទាក់ទងល្អ ជាមួយអាជ្ញាធរ និងអ្នកពាក់ព័ន្ធ
- មានកាយសម្បទាមាំមួន
- ស្ត្រីត្រូវបានលើកទឹកចិត្ត។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមមន្ត្រី បុគ្គលិក និងសាធារណៈជនដែលមានចំណាប់អារម្មណ៍ក្នុងការចូលរួមវគ្គបណ្តុះបណ្តាល សូមអញ្ជើញមកទទួល និងដាក់ពាក្យនៅ.........................រៀងរាល់ម៉ោងធ្វើការ ចាប់ពីថ្ងៃជូនដំណឹងនេះរហូតដល់ថ្ងៃទី.........ខែ.........ឆ្នាំ២០....( ដើម្បីទទួលបានពាក្យសុំចុះឈ្មោះចូលរៀន និងគំរូប្រវត្តិរូបបេក្ខជន/បេក្ខនារីអាចមកទំនាក់ទំនងការិយាល័យរដ្ឋបាលរៀងរាល់ម៉ោងធ្វើការ )។

កន្លែងទទួលពាក្យនៅការិយាល័យរដ្ឋបាល.......................................................................
**លេខទំនាក់ទំនង**...................................៖

សំណុំបែបបទដែលបេក្ខជន/បេក្ខនារី ត្រូវបំពេញ និងភ្ជាប់មកជាមួយមាន៖

- ពាក្យស្នើសុំចុះឈ្មោះចូលរៀន ចំនួន០២ច្បាប់
- ជីវប្រវត្តិសង្ខេបផ្ទាល់ខ្លួនមានបិទរូបថត (៤ គុណ ៦ ) ចំនួន០២ច្បាប់
- សញ្ញាបត្របច្ចេកទេសជំនាញ ឬវិញ្ញាបនបត្រមានតម្លៃស្មើ ចំនួន០២ច្បាប់
- សញ្ញាបត្រចំណេះទូទៅ ចំនួន០២ច្បាប់
- សេចក្តីបញ្ជាក់ពីប្រធានអង្គភាព ចំនួន០២ច្បាប់
- អត្តសញ្ញាណប័ណ្ណសំគាល់ខ្លួន ចំនួន០២ច្បាប់

**ប្រធានអង្គភាពរៀបចំវគ្គបណ្តុះបណ្តាល**

**ឧបសម្ព័ន្ធទី២: ពាក្យស្នើសុំចុះឈ្មោះចូលរៀន និងប្រវត្តិរូបសង្ខេប**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួង**...............
**អង្គភាព**.............

**ពាក្យស្នើសុំចុះឈ្មោះចូលរៀន**
**វគ្គបណ្តុះបណ្តាលអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ...................................អក្សរឡាតាំង.............................ភេទ........
ថ្ងៃខែឆ្នាំកំណើត..........................................................................សញ្ជាតិ.....................
ទីកន្លែងកំណើត...........................................................................................................
លេខទូរស័ព្ទផ្ទាល់ខ្លួន............................................អ៊ីម៉ែល..................................................
លេខទូរស័ព្ទអង្គភាព............................................អ៊ីម៉ែល..................................................។

**សូមគោរពជូន**

..................................................................................

**តាមរយៈ**.................................................................................................................
**កម្មវត្ថុ**...................................................................................................................

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើខ្ញុំបាទ/នាងខ្ញុំ សូមគោរពជូន............................មេត្តាអនុញ្ញាត ឱ្យខ្ញុំបាទ/នាងខ្ញុំបានចុះឈ្មោះចូលរៀនវគ្គបណ្តុះបណ្តាលអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម ................................ មេត្តាពិនិត្យ និងអនុញ្ញាតឱ្យខ្ញុំបាទ/នាងខ្ញុំ បានចុះឈ្មោះចូលរៀនដោយសេចក្តីអនុគ្រោះ។

សូម ......................... មេត្តាទទួលនូវការគោរពអំពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ...........................ខែ................ឆ្នាំ................ព.ស............
ធ្វើនៅ......................ថ្ងៃទី......................ខែ..............ឆ្នាំ............

**ហត្ថលេខាសាមីខ្លួន**

**បានឃើញ និងឯកភាព**
**ប្រធានអង្គភាព**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រូបថត
៤ x ៦

## ប្រវត្តិរូបសង្ខេប

ជីវប្រវត្តិសង្ខេប

| | | | |
|---|---|---|---|
| គោត្តនាម និង នាម | | ភេទ | |
| ជាអក្សរឡាតាំង | | | |
| សញ្ជាតិ | | ថ្ងៃ ខែ ឆ្នាំកំណើត | |
| ទីកន្លែងកំណើត | | | |
| ទីលំនៅបច្ចុប្បន្ន | | | |
| ឈ្មោះអង្គភាព | | | |
| អាសយដ្ឋានអង្គភាព | | | |
| ទូរស័ព្ទ (១)៖ | | អ៊ីម៉ែល៖ | |

**កម្រិតការអប់រំ (កម្រិតសញ្ញាបត្រ ២ ចុងក្រោយ)**

| ឈ្មោះស្ថាប័នបណ្តុះបណ្តាល ប្រទេស | កម្រិតសញ្ញាបត្រ | ឆ្នាំសិក្សា | |
|---|---|---|---|
| | | ពីឆ្នាំ | ដល់ឆ្នាំ |
| | | | |
| | | | |
| | | | |
| | | | |

## វគ្គបណ្តុះបណ្តាល ខ្លីវែងដែលបានចូលរួម

| ឈ្មោះវគ្គ | ការបរិច្ឆេទ (ថ្ងៃ ខែ ឆ្នាំ) | ស្ថាប័នរៀបចំ | ប្រទេស | អ្នកឧបត្ថម្ភ |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |

## បទពិសោធន៍បម្រើការងារ

| | | | |
|---|---|---|---|
| មុខរបរបច្ចុប្បន្ន និងតួនាទី | | | |
| ការងារដែលទទួលខុសត្រូវ | | | |
| អតីតភាពការងារ និងតួនាទី | អង្គភាព/ស្ថាប័ន | ឆ្នាំបម្រើការងារ | |
| | | ពីឆ្នាំ | ដល់ឆ្នាំ |
| | | | |
| | | | |

**ព័ត៌មានសម្រាប់ទំនាក់ទំនង** (អ្នកទំនាក់ទំនងក្នុងពេលមានបញ្ហា)

| | |
|---|---|
| ឈ្មោះអ្នកត្រូវទំនាក់ទំនង | |
| ត្រូវជា | |
| អាសយដ្ឋាន | |
| ព័ត៌មានលម្អិត (ទូរស័ព្ទ / អ៊ីម៉ែល) | |

ធ្វើនៅ...................... ថ្ងៃទី..........ខែ...................ឆ្នាំ............

ហត្ថលេខា និងឈ្មោះសាមីខ្លួន

ថ្ងៃ....................ខែ..........ឆ្នាំ.......... ព.ស ២៥៦...

.......... ថ្ងៃទី..........ខែ...........ឆ្នាំ២០.......

បានឃើញ និងឯកភាព

**ប្រធានអង្គភាព**

## ឧបសម្ព័ន្ធទី៣: លិខិតឧទ្ទេសនាមចូលរួមវគ្គបណ្តុះបណ្តាល

### ក្បាលទំព័រលិខិត ( Letter head ) របស់អង្គភាពគ្រប់គ្រងបេក្ខជន/បេក្ខនារីចូលរួមវគ្គបណ្តុះបណ្តាលអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**អង្គភាព**........................................................................

**សូមគោរពជូន**

**លោកប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

**កម្មវត្ថុ៖** សំណើសុំចាត់មន្ត្រី/បុគ្គលិក ចំនួន...........រូប ចូលរួមវគ្គបណ្តុះបណ្តាលសម្រាប់អ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**យោង៖** - សេចក្តីជូនដំណឹងរបស់អង្គភាព....................ចុះថ្ងៃទី.......ខែ.............ឆ្នាំ..........ស្តីពី ការជ្រើសរើសបេក្ខជន/បេក្ខនារីឱ្យចូលរួមវគ្គបណ្តុះបណ្តាលសម្រាប់អ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- លទ្ធផលពីការវាយតម្លៃ របស់ក្រុមការងារវាយតម្លៃផ្អែកលក្ខណៈវិនិច្ឆ័យបេក្ខជន/បេក្ខនារីចូលរួមវគ្គ បណ្តុះបណ្តាលសម្រាប់អ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **លោកប្រធាន** មេត្តាជ្រាបថា៖ អង្គភាព..................................... សូមអនុញ្ញាតចាត់បញ្ជូន៖

១. ឈ្មោះ............................................... តួនាទី........................................................

២. ឈ្មោះ............................................... តួនាទី........................................................

ដើម្បីចូលរួមក្នុងវគ្គបណ្តុះបណ្តាលសម្រាប់អ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃ...........ខែ..........ឆ្នាំ...........ដល់ថ្ងៃ...............ខែ.........ឆ្នាំ......... នៅ...................................។

សេចក្តីដូចបានជម្រាបជូនខាងលើសូម លោកប្រធាន មេត្តាពិនិត្យ និងសម្រេចតាមការគួរ។

សូមលោកប្រធាននាយកដ្ឋាន មេត្តាទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ។

**ឈ្មោះ ហត្ថលេខា និងត្រា ប្រធានអង្គភាព**

..................................................................

**<u>ចម្លងជូន៖</u>**

..............

# ឧបសម្ព័ន្ធទី៤: ប្រធានបទបណ្តុះបណ្តាល

| ល.រ | មុខវិជ្ជា | ចំនួនម៉ោង |
|---|---|---|
| | I. **ការផ្សព្វផ្សាយកសិកម្ម** ( ៧០% = ៥៣៣ ម៉ោង ) | |
| ១ | **ប្រព័ន្ធនៃការផ្សព្វផ្សាយកសិកម្ម** | ១៤៩ |
| | ទិដ្ឋភាពទូទៅ និងសារៈសំខាន់នៃការផ្សព្វផ្សាយកសិកម្ម និងសេវាកម្មប្រឹក្សាយោបល់ | ១៤ |
| | ការផ្សព្វផ្សាយកសិកម្មក្នុងសតវត្សទី២១ | ៧ |
| | គោលនយោបាយផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៧ |
| | លំនាំដើម ដំណើរការ និងវិធីសាស្ត្រក្នុងការផ្សព្វផ្សាយកសិកម្ម | ២៨ |
| | គំរូផ្ទេរបច្ចេកវិទ្យា | ១៤ |
| | ការពង្រឹងប្រព័ន្ធផ្សព្វផ្សាយ និងប្រព័ន្ធប្រឹក្សាយោបល់ | ១៤ |
| | ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងសកម្មភាពផ្សព្វផ្សាយកសិកម្ម | ១៤ |
| | ការធ្វើផែនការក្នុងការផ្សព្វផ្សាយការសរសេរគម្រោងស្នើសុំការតាមដាន និងវាយតម្លៃ | ១៤ |
| | ការគ្រប់គ្រងផ្អែកលើលទ្ធផល | ៩ |
| | ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃប្រសិទ្ធភាពពីការទទួលយក និងការសាយភាយបច្ចេកទេសកសិកម្ម | ១៤ |
| | វិធីសាស្ត្រផ្សព្វផ្សាយ ៥<br>▪ កិច្ចសន្យាជួលអ្នកក្រៅ<br>▪ ភាពជាដៃគូរវាងស្ថាប័នរដ្ឋ និងវិស័យឯកជន<br>▪ គាំទ្រសហគមន៍កសិកម្ម/អង្គការកសិករ<br>▪ ការរៀនសូត្រពីកសិករទៅកសិករ<br>▪ សេវាផ្សព្វផ្សាយសាធារណៈដោយស្ថាប័នរដ្ឋ | ១៤ |
| ២ | **ការផ្សព្វផ្សាយកសិកម្មជនបទជាមួយកសិករខ្នាតតូច** | ៤២ |
| | និយមន័យ និងលក្ខណៈរបស់កសិករខ្នាតតូច និងកសិកម្មខ្នាតតូច | ៧ |
| | ឧបសគ្គ និងភាពចាំបាច់ក្នុងការអភិវឌ្ឍកសិករខ្នាតតូច | ៧ |
| | យុទ្ធសាស្ត្រ និងវិធីសាស្ត្រនៃការអភិវឌ្ឍកសិកម្មខ្នាតតូច | ១៤ |

| | | |
|---|---|---|
| | ជោគជ័យ និងគំរូក្នុងការអភិវឌ្ឍកសិករខ្នាតតូច | ១៤ |
| ៣ | **ការអភិវឌ្ឍកសិកម្មប្រកបដោយនិរន្តរភាព** | **៨៤** |
| | សារៈសំខាន់ និងគោលគំនិតនៃកសិកម្មប្រកបដោយចីរភាព | ១៤ |
| | បច្ចេកទេស និងឥទ្ធិពលនៃការផ្តល់បច្ចេកវិទ្យាកសិកម្មប្រកបដោយចីរភាព | ១៤ |
| | ការគ្រប់គ្រងដីធ្លីប្រកបដោយនិរន្តរភាពក្នុងវិស័យកសិកម្ម | ១៤ |
| | កសិកម្មសរីរាង្គ | ១៤ |
| | ប្រព័ន្ធកសិកម្មចម្រុះតាមតំបន់កៀស្រ-បរិស្ថាន | ២៨ |
| ៤ | **ការប្រាស្រ័យទាក់ទងក្នុងការងារកសិកម្ម** | **៤២** |
| | ការគ្រប់គ្រងចំណេះដឹងក្នុងការផ្សព្វផ្សាយកសិកម្មរួមមានការជ្រើសរើសប្រព័ន្ធផ្សព្វផ្សាយ ការផលិតពហុព័ត៌មាន និងបណ្តាញព័ត៌មាន | ១៤ |
| | វិធីសាស្រ្តផ្សព្វផ្សាយដោយប្រើប្រព័ន្ធព័ត៌មានវិទ្យា (សេវាផ្តល់ព័ត៌មានបច្ចេកទេសកសិកម្មដល់កសិករ និងអតិថិជន កម្មវិធីទូរស័ព្ទដៃ គេហទំព័រ...) | ១៤ |
| | ហានិភ័យ និងវិបត្តិនៃទំនាក់ទំនងក្នុងវិស័យកសិកម្ម និងធនធានធម្មជាតិ | ១៤ |
| ៥ | **ការគ្រប់គ្រងគម្រោង និងភាពជាអ្នកដឹកនាំ** | **៧០** |
| | ទ្រឹស្តីក្នុងភាពជាអ្នកដឹកនាំ និន្នាការ និងការអភិវឌ្ឍ | ៧ |
| | វិធីសាស្រ្តក្នុងការដឹកនាំស្ថាប័នប្រកបដោយប្រសិទ្ធភាព | ៧ |
| | សារៈសំខាន់ និងគោលការណ៍នៃការគ្រប់គ្រងគម្រោង | ១៤ |
| | ទស្សនទាន និងគំរូនានានៅក្នុងការធ្វើផែនការកម្មវិធី កិច្ចការរដ្ឋបាល ការគ្រប់គ្រង និងសម្របសម្រួល | ១៤ |
| | គំរូ និងវិធីសាស្រ្តតាមដាន និងវាយតម្លៃ | ១៤ |
| | ការវាយតម្លៃកម្មវិធីផ្សព្វផ្សាយកសិកម្ម និងសេវាប្រឹក្សាយោបល់ | ១៤ |
| ៦ | **ទីផ្សារកសិកម្ម និងការគ្រប់គ្រងអាជីវកម្ម** | **៦៣** |
| | មូលដ្ឋានគ្រឹះ និងការអនុវត្តការគ្រប់គ្រងទីផ្សារកសិកម្ម និងការគ្រប់គ្រងធុរកិច្ចកសិកម្ម | ១៤ |
| | ភាពជាសហគ្រិនកសិកម្ម | ៧ |
| | ការអភិវឌ្ឍសហគ្រាសខ្នាតតូច និងមធ្យម | ១៤ |

| | | |
|---|---|---|
| | ការផ្សារភ្ជាប់ផលិតផលទៅកាន់ទីផ្សារ និងការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា | ១៤ |
| | ការចូលរួមចំណែកផ្នែកសេដ្ឋកិច្ចនៃការផ្សព្វផ្សាយកសិកម្មដល់ការអភិវឌ្ឍកសិកម្ម និងការអភិវឌ្ឍជនបទ | ១៤ |
| ៧ | **តួនាទីយេនឌ័រ និងការបង្កើនសិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីក្នុងវិស័យកសិកម្ម** | **២០** |
| | គោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម និងតួនាទីភារកិច្ចអ្នកពាក់ព័ន្ធ | ១០ |
| | ការផ្តល់ ឬការបង្កើនសិទ្ធិអំណាច ផ្នែកសេដ្ឋកិច្ចដល់ស្ត្រីក្នុងវិស័យកសិកម្ម | ១០ |
| ៨ | **ប្រព័ន្ធធានាដោយមានការចូលរួម** ( PGS-Participatory Guarantee System ) | **៦៣** |
| | បរិបទក្នុងការធ្វើកសិកម្មរបស់កសិករខ្នាតតូច | ៧ |
| | ជម្រើសអាទិភាពសម្រាប់កសិករខ្នាតតូច | ៧ |
| | និយមន័យ ប្រព័ន្ធធានាដោយមានការចូលរួម | ៧ |
| | អ្វីជាអត្ថប្រយោជន៍របស់ ប្រព័ន្ធធានាដោយមានការចូលរួម | ៧ |
| | គោលការណ៍គ្រឹះរបស់ប្រព័ន្ធធានាដោយមានការចូលរួម | ៧ |
| | ជំរុញការអនុវត្តកសិកម្មសរីរាង្គអនុលោមតាមប្រព័ន្ធធានាដោយមានការចូលរួម | ១៤ |
| | ដំណើរការរបស់ ប្រព័ន្ធធានាដោយមានការចូល និងការត្រួតពិនិត្យកសិដ្ឋានមុនពេលផ្តល់វិញ្ញាបនបត្របញ្ជាក់ | ៧ |
| សរុបរងម៉ោងសិក្សា | | **៥៥៣ ម៉ោង** |
| II. **បច្ចេកទេសកសិកម្មថ្មីៗ ដែលធន់នៅនឹងការប្រែប្រួលអាកាសធាតុ** ( **៣០**% = **២២៨ ម៉ោង** ) | | |
| ១ | **ការអនុវត្តកសិកម្មល្អ** ( CamGAP ) | **៨៤** |
| | និយមន័យនៃ ការអនុវត្តកសិកម្មល្អជាសកល ( GlobalGAP ) | ១០.៥ |
| | និយមន័យនៃ ការអនុវត្តកសិកម្មល្អ | ១០.៥ |
| | ការអនុវត្តកសិកម្មល្អ ផ្នែកសុវត្ថិភាពចំណីអាហារ | ២៨ |
| | ការអនុវត្តកសិកម្មល្អ ដើម្បីគ្រប់គ្រងសុវត្ថិភាពចំណីអាហារ | ២៨ |

| | | |
|---|---|---|
| | ប្រព័ន្ធផ្តល់វិញ្ញាបនបត្រ សម្រាប់ការអនុវត្តកសិកម្មល្អ | ៧ |
| ២ | **ការអនុវត្តការចិញ្ចឹមសត្វល្អ** | **៤៦** |
| | និយមន័យ ការអនុវត្តការចិញ្ចឹមសត្វល្អ | ១១ |
| | ការអនុវត្តការចិញ្ចឹមសត្វល្អ (កសិដ្ឋាន ចំណី ការគ្រប់គ្រងកសិដ្ឋាន ការគ្រប់គ្រងសុខភាពសត្វ ការដឹកជញ្ជូន ការរក្សាទុក និងការកត់ត្រា) | ២៨ |
| | ប្រព័ន្ធផ្តល់វិញ្ញាបនបត្រ សម្រាប់ការអនុវត្តការចិញ្ចឹមសត្វល្អ | ៧ |
| ៣ | **វារីវប្បកម្ម** | **២៨** |
| | វារីវប្បកម្មដែលមានសក្តានុពល | ១៤ |
| | ការកែច្នៃផលិតផលជលផល | ១៤ |
| ៤ | **ផលិតកម្មដំណាំកៅស៊ូដែលធន់នឹងការប្រែប្រួលអាកាសធាតុ** | **២១** |
| | ផលិតកម្មដំណាំកៅស៊ូដែលធន់នឹងការប្រែប្រួលអាកាសធាតុ | ២១ |
| ៥ | **ព្រៃឈើ** | **៤៩** |
| | ផលប្រយោជន៍នៃចម្ការឈើដាំសម្រាប់សេដ្ឋកិច្ច សង្គម និងគុណភាពដី | ១៤ |
| | ការប្រើប្រាស់ផល និងអនុផលព្រៃឈើប្រកបដោយនិរន្តរភាព | ១៤ |
| | ការគ្រប់គ្រងព្រៃឈើដោយមានការចូលរួម (សហគមន៍ និងវិស័យឯកជន) | ៧ |
| | ការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព | ៧ |
| | ការគ្រប់គ្រងបញ្ហាភ្លើងឆេះព្រៃ និងយន្តការបង្ការ និងទប់ស្កាត់ | ៧ |
| សរុបរងម៉ោងសិក្សា | | **២២៨ ម៉ោង** |
| | **• បទបង្ហាញ និងទស្សនកិច្ចសិក្សា (៦៣ ម៉ោង)** | |
| ១ | ទស្សនកិច្ចសិក្សា | ២១ |
| ២ | បទបង្ហាញ | ៤២ |
| សរុបរងម៉ោងសិក្សា | | ៦៣ ម៉ោង |
| **សរុបម៉ោងសិក្សា** | | **៨២៤ ម៉ោង** |

- កំណត់យក ១ខែ ស្មើនឹង ២២ថ្ងៃ ដោយដកថ្ងៃឈប់សម្រាក ដូច្នេះរយៈពេលបណ្តុះបណ្តាលចំនួន ៦ខែ ត្រូវនឹង ១៣២ថ្ងៃ ស្មើនឹង៨២៤ម៉ោង
- ទស្សនកិច្ចសិក្សានឹងធ្វើឡើងក្នុងរយៈពេល២ខែម្តង សរុបទស្សនកិច្ចសិក្សាមានចំនួន០៣ដង ស្មើនឹង២១ម៉ោង
- ក្រោយត្រលប់ពីហាត់ការតាមខេត្តសាមីរៀងៗខ្លួន សិក្ខាកាមត្រូវធ្វើបទបង្ហាញពីលទ្ធផលនៃការហាត់ការរបស់ខ្លួន។ ដោយការហាត់ការតាមអង្គភាពសាមីមាន៦ដងក្នុងមួយពេញវគ្គបណ្តុះបណ្តាល ហើយក្នុងការធ្វើបទបង្ហាញម្តងត្រូវចំណាយពេលមួយថ្ងៃពេញ ដូចនេះការធ្វើបទបង្ហាញ០៦ដង ត្រូវប្រើពេល០៦ថ្ងៃស្មើនឹង៤១ម៉ោង។

# ឧបសម្ព័ន្ធទី៥: ការវាយតម្លៃសមត្ថភាពអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ  សាសនា  ព្រះមហាក្សត្រ
* * * *

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
* * * *

## ទម្រង់តាមដាន និងវាយតម្លៃសមត្ថភាព
## អ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ទម្រង់នេះត្រូវបានប្រើដោយក្រុមការងារវាយតម្លៃនៃនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្នុងដំណើរការវាយតម្លៃសមត្ថភាពរបស់អ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយសហការជាមួយអង្គភាពសាមី។

- កិច្ចសម្ភាសន៍ជាមួយអ្នកគ្រប់គ្រងរបស់អ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- កិច្ចសម្ភាសន៍ជាមួយអ្នកទទួលសេវាពីអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (២-៣នាក់)។

### ១. ព័ត៌មានទូទៅ

### ក. អ្នកវាយតម្លៃ

- កាលបរិច្ឆេទ.......................................................................................................
- ឈ្មោះអ្នកវាយតម្លៃ តួនាទី ភេទ និងលេខទូរស័ព្ទ..................................................
- ឈ្មោះស្ថាប័ន និងអាសយដ្ឋានទំនាក់ទំនងអ្នកវាយតម្លៃ........................................

### ខ.អ្នកផ្តល់សម្ភាសន៍

១). លោក/លោកស្រី.............................ភេទ........តួនាទី.......................................................
ទីកន្លែងធ្វើការ.......................................................................................................

២). លោក/លោកស្រី.............................ភេទ........តួនាទី.......................................................
ទីកន្លែងធ្វើការ.......................................................................................................

៣).លោក/លោកស្រី.............................ភេទ.........តួនាទី.......................................................
ទីកន្លែងធ្វើការ.......................................................................................................

### ២. លទ្ធផលសម្ភាសន៍

ការដាក់ពិន្ទុ៖ ពិន្ទុ (១)=ខ្សោយ (២)=មធ្យម (៣)=ល្អ (៤)=ល្អណាស់ ។ ពិន្ទុសរុប (......./២៨)។

| លរ | ប្រធានបទ | ពិន្ទុប្រធានអង្គភាព | ពិន្ទុអ្នកទទួលសេវាផ្ទាល់ | | | | ពិន្ទុសាមីខ្លួន | ពិន្ទុសរុប |
|---|---|---|---|---|---|---|---|---|
| | | | អ្នកទី១ | អ្នកទី២ | អ្នកទី៣ | ពិន្ទុមធ្យមភាគ | | |
| ១ | **ផែនការ និងការគ្រប់គ្រង៖** រៀបចំផែនការផ្សព្វផ្សាយការអនុវត្ត និងតាមដានវាយតម្លៃ | | | | | | | |
| ២ | **ជំនាញបច្ចេកទេស៖** ប្រើប្រាស់វិធីសាស្ត្រថ្មីៗក្នុងការងារផ្សព្វផ្សាយកសិកម្ម | | | | | | | |
| ៣ | **ទំនាក់ទំនង និងសហការ៖** សហការ ផ្តល់សេវាផ្សព្វផ្សាយជាមួយស្ថាប័នពាក់ព័ន្ធ អង្គភាពជំនាញ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន | | | | | | | |
| ៤ | **ប្រសិទ្ធភាពការអនុវត្តការងារ៖** សេវាផ្សព្វផ្សាយដែលបានផ្តល់ឆ្លើយតបតាមតម្រូវការ និងស្ថានភាពជាក់ស្តែង | | | | | | | |
| ៥ | **របាយការណ៍៖** វិភាគទិន្នន័យ និងចងក្រងរបាយការណ៍ការផ្សព្វផ្សាយកសិកម្ម | | | | | | | |
| ៦ | **លើកកម្ពស់ការចូលរួម និងពង្រឹងអំណាចស្ត្រីក្នុងការផ្សព្វផ្សាយកសិកម្ម៖** ចំណេះដឹង និងការប្រើប្រាស់ព័ត៌មានវិទ្យាក្នុងការផ្សព្វផ្សាយ | | | | | | | |
| ៧ | **បុគ្គលិកលក្ខណៈ៖** ការចូលរួម, ការយកចិត្តទុកដាក់ក្នុងការងារ, ការបង្កើត និងលើកគំនិតថ្មីៗសម្រាប់អង្គភាព។ | | | | | | | |
| | **ពិន្ទុសរុប** | | | | | | | |

- ជារួម តើអ្នកនឹងវាយតម្លៃអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនេះយ៉ាងដូចម្តេច?

☐ មិនល្អ (១០) ☐ មធ្យម (១៦) ☐ ល្អ (២២) ☐ ល្អណាស់ (២៨)

## ៣.សន្និដ្ឋានរួម និងអនុសាសន៍

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

## ឧបសម្ព័ន្ធទី៦ តួនាទី និងភារកិច្ចអង្គភាពពាក់ព័ន្ធ

❖ **នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

- រៀបចំ ចងក្រង កែសម្រួល និងផ្សព្វផ្សាយពីគោលការណ៍ណែនាំ អ្នកឯកទេសផ្សព្វផ្សាយកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ដល់ អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន
- រៀបចំផែនការសកម្មភាព និងថវិកាសម្រាប់វគ្គបណ្តុះបណ្តាល
- សហការជាមួយគ្រឹះស្ថានអប់រំកសិកម្ម អង្គភាពជំនាញ និងអង្គភាពផ្តល់សេវាផ្សព្វផ្សាយកសិកម្មដៃគូអភិវឌ្ឍន៍ និងវិស័យឯកជនក្នុងការរៀបចំនិងផ្តល់វគ្គបណ្តុះបណ្តាល
- តាមដាន និងវាយតម្លៃសមត្ថភាពរបស់អ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយសហការជាមួយអង្គភាពដែលអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបំពេញការងារ
- រៀបចំរបាយការណ៍លទ្ធផលនៃការវាយតម្លៃសមត្ថភាពអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដាក់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដើម្បីធ្វើការទទួលស្គាល់ជាផ្លូវការ
- កែលម្អកម្មវិធីបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ធ្វើបច្ចុប្បន្នភាពចំនួនអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដាក់បញ្ចូលទៅក្នុងគេហទំព័រផ្សព្វផ្សាយកសិកម្មកម្ពុជា។

❖ **គ្រឹះស្ថានអប់រំកសិកម្ម និងអង្គភាពជំនាញក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

- អនុវត្តតាមគោលការណ៍ណែនាំសម្រាប់ អ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- រៀបចំផែនការសកម្មភាព និងថវិកាសម្រាប់វគ្គបណ្តុះបណ្តាល
- សហការជាមួយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្នុងការ

រៀបចំបើកវគ្គបណ្តុះបណ្តាល (ចុះអនុស្សរណៈនៃកិច្ចព្រមព្រៀង)

- ផ្តល់សិក្ខាកាមដើម្បីចូលរួមវគ្គបណ្តុះបណ្តាលឱ្យក្លាយជាអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ផ្តល់គ្រូបង្គោលដើម្បីបណ្តុះបណ្តាលអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- សម្របសម្រួលក្នុងការបំពេញការងាររបស់ អ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- សហការជាមួយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការតាមដាន និងវាយតម្លៃសមត្ថភាព ព្រមទាំងការវាយតម្លៃទទួលស្គាល់អ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- រៀបចំ និងធ្វើបច្ចុប្បន្នភាពអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ និងផ្ញើមកនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- សហការលើការងារផ្សេងៗទៀតតាមការស្នើសុំរបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

❖ **វិស័យឯកជន និងដៃគូអភិវឌ្ឍន៍**

- អនុវត្តតាម គោលការណ៍ណែនាំសម្រាប់អ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- រៀបចំផែនការសកម្មភាព និងថវិកាសម្រាប់វគ្គបណ្តុះបណ្តាល
- សហការជាមួយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គភាពរៀបចំវគ្គបណ្តុះបណ្តាលក្នុងការរៀបចំវគ្គបណ្តុះបណ្តាល
- ផ្តល់សិក្ខាកាមដើម្បីចូលរួមវគ្គបណ្តុះបណ្តាលឱ្យក្លាយជាអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ផ្តល់គ្រូបង្គោលដើម្បីបណ្តុះបណ្តាលអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- សម្របសម្រួលក្នុងការបំពេញការងាររបស់អ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- សហការជាមួយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការតាមដាន និងវាយតម្លៃសមត្ថភាព ព្រមទាំងការវាយតម្លៃទទួលស្គាល់អ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- រៀបចំ និងធ្វើបច្ចុប្បន្នភាព ចំនួនអ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ និងផ្ញើមកនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- សហការលើការងារផ្សេងៗទៀត តាមការស្នើសុំរបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ឧបសម្ព័ន្ធទី៧: ប្រភេទលិខិតចាំបាច់សម្រាប់ដំណើរការបណ្តុះបណ្តាល

| ល.រ | ប្រភេទលិខិត | អង្គភាពសាមី | អង្គភាពទទួល |
|---|---|---|---|
| ១ | លិខិតស្នើសុំការអនុញ្ញាតរៀបចំវគ្គ បណ្តុះបណ្តាល និងកិច្ចសហការ។ | អង្គភាពរៀបចំវគ្គបណ្តុះបណ្តាល | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ២ | លិខិតជូនដំណឹងពីដំណើរនៃវគ្គបណ្តុះបណ្តាល។ | អង្គភាពរៀបចំវគ្គបណ្តុះបណ្តាល | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ៣ | លិខិតស្នើសុំការតាមដានវាយតម្លៃសមត្ថភាព និងទទួលស្គាល់អ្នកឯកទេសផ្សព្វផ្សាយ។ | អង្គភាពរៀបចំវគ្គបណ្តុះបណ្តាល | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |

## ឧបសម្ព័ន្ធទី៨ គំរូផែនការថវិកាសម្រាប់វគ្គបណ្តុះបណ្តាល

| ល.រ | បរិយាយ | ឯកត្តា | តម្លៃ/ឯកត្តា (រៀល) | បរិមាណ | សរុប (រៀល) |
|---|---|---|---|---|---|
| **១. ដំណើរការជ្រើសរើស** | | | | | |
| **១.១** | **ប្រជុំក្រុមការងារជ្រើសរើសបេក្ខភាព** | | | | |
| | អាហារសម្រន់ | ថ្ងៃ/នាក់ | | | |
| | សម្ភារប្រជុំ | នាក់ | | | |
| | ប្រាក់ឧបត្ថម្ភធ្វើដំណើរ | ដង/នាក់ | | | |
| **១.២** | **ផ្សព្វផ្សាយការជ្រើសរើស** | | | | |
| | ការរៀបចំឯកសារផ្សព្វផ្សាយ | រួម | | | |
| | ការផ្សព្វផ្សាយតាមវិទ្យុ | ដង | | | |
| **២. ដំណើរការបណ្តុះបណ្តាល** | | | | | |
| **២.១** | **ការបណ្តុះបណ្តាល** | | | | |
| | ការចំណាយលើបន្ទប់ប្រជុំ | ថ្ងៃ | | | |
| | អាហារសម្រន់ | ថ្ងៃ/នាក់ | | | |
| **២.២** | **ការឧបត្ថម្ភគ្រូបណ្តុះបណ្តាល** | | | | |
| | ប្រាក់សេវាបណ្តុះបណ្តាល | ថ្ងៃ/នាក់ | | | |
| | ប្រាក់ធ្វើដំណើរ | ដង/នាក់ | | | |
| | ប្រាក់ឧបត្ថម្ភ ការស្នាក់នៅ និង អាហារ | ថ្ងៃ/នាក់ | | | |
| **២.៣** | **ការឧបត្ថម្ភសិក្ខាកាម** | | | | |
| | ប្រាក់ធ្វើដំណើរ | ដង/នាក់ | | | |
| | ប្រាក់ឧបត្ថម្ភ | ថ្ងៃ/នាក់ | | | |
| **២.៤** | **សម្ភារបណ្តុះបណ្តាល** | | | | |

| | | | | | |
|---|---|---|---|---|---|
| | សម្ភារសម្រាប់វគ្គបណ្ដុះបណ្ដាល | រួម | | | |
| | បដារ | ចំនួន | | | |
| | វិញ្ញាបនបត្រ | សន្លឹក | | | |
| | ឯកសារសម្រាប់សិក្ខាកាម | នាក់ | | | |
| ២.៥ | **ទស្សនកិច្ចសិក្សា** | | | | |
| | ថ្លៃជួលរថយន្ត | ថ្ងៃ | | | |
| | អាហារថ្ងៃត្រង់ | ថ្ងៃ/នាក់ | | | |
| | វត្ថុអនុស្សាវរីយ៍ | ចំនួន | | | |

## ឧបសម្ព័ន្ធទី៩ គំរូផែនការសកម្មភាព

| ល.រ | សកម្មភាព | ឆ្នាំ...... | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ១ | ការរៀបចំក្រុមការងារជ្រើសរើសបេក្ខជនចូលរួមវគ្គបណ្ដុះបណ្ដាល | | | | | | | | | | | | |
| ២ | ការផ្សព្វផ្សាយ | | | | | | | | | | | | |
| ៣ | ការរៀបចំឯកសារផ្សព្វផ្សាយ | | | | | | | | | | | | |
| ៤ | ការផ្សព្វផ្សាយ ពីការជ្រើសរើសបេក្ខជនចូលរួមវគ្គបណ្ដុះបណ្ដាល | | | | | | | | | | | | |
| ៥ | ដំណើរការជ្រើសរើសបេក្ខជន | | | | | | | | | | | | |
| ៦ | លិខិតស្នើសុំការអនុញ្ញាតរៀបចំវគ្គបណ្ដុះបណ្ដាល និងកិច្ចសហការ | | | | | | | | | | | | |
| ៧ | ដំណើរការបណ្ដុះបណ្ដាល | | | | | | | | | | | | |
| ៨ | ការតាមដាន និងវាយតម្លៃសមត្ថភាពអ្នកឯកទេស | | | | | | | | | | | | |
| ៩ | ការទទួលស្គាល់ទទួលស្គាល់ជាផ្លូវការនៃ អ្នកឯកទេស | | | | | | | | | | | | |

# ឯកសារយោង


១. គោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជាឆ្នាំ២០១៥។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

២. ការអនុវត្តកសិកម្មល្អកម្ពុជា(CAM-GAP) អគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឆ្នាំ២០១៦។

៣. Draft for discussion, outline for the Professional In-Service Training of Trainers of Agricultural Extension Specialists , Royal University of Agriculture, Ministry of Agriculture Forestry and Fisheries, July 2017.

៤. គោលការណ៍ណែនាំស្តីពី តួនាទីយេនឌ័រ និងការបង្កើនសិទ្ធអំណាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីក្នុងវិស័យកសិកម្ម កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE) ឆ្នាំ២០១៧។

៥. បទបង្ហាញប្រព័ន្ធធានាដោយមានការចូល អង្គការការីតាសកម្ពុជាខែធ្នូ ឆ្នាំ២០១៨។

៦. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

៧. កម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញផ្សព្វផ្សាយកសិកម្ម។ សាកលវិទ្យាល័យភូមិន្ទកសិកម្មឆ្នាំ២០២០

៨. របាយការណ៍ស្តីពីការពិនិត្យឡើងវិញ លើគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា ឆ្នាំ២០១៥ ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខែសីហា ឆ្នាំ២០២០។

៩. គោលការណ៍ណែនាំសម្រាប់ទីប្រឹក្សាផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខែធ្នូ ឆ្នាំ២០២០។




**អាសយដ្ឋាន** : ផ្ទះលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចម្ការមន រាជធានីភ្នំពេញ

**ទូរស័ព្ទលេខ** : ០៧៧ ៥១៤ ០៥១

Facebook : department of extension for agriculture, forestry and fisheries

**គេហទំព័រ** : www.khmeragri.info / deaff.maff.gov.kh